


# ជី វ ប្រ វ ត្តិ

របស់

លោក ស៊ីង ទួន ទីប្រឹក្សា (២០០៤-២០០៧) និងជាអតីត ប្រធានប្រតិបត្តិ(២០០០-២០០៤) គណៈកម្មការនាយកនៃសហព័ន្ធខ្មែរកម្ពុជាក្រោម ពិភពលោក។

កើតឆ្នាំមមែ សប្តស័ក ព.ស.២៤៩៩ ត្រូវនឹងថ្ងៃទី១២ ខែមិនា គ.ស.១៩៥៦

ស្លាប់ថ្ងៃអាទិត្យ២កើត ខែផល្គុន ឆ្នាំចអដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ គ.ស.២០០៧

លោកស៊ីង ទួន អតីតប្រធានប្រតិបត្តិ និងបច្ចុប្បន្ន ជាទីប្រឹក្សា គណៈកម្មការនាយក នៃសហព័ន្ធខ្មែរកម្ពុជាក្រោម ពិភពលោក។ ពេលចូលសញ្ជាតិអាមេរិកាំងមានឈ្មោះថា **Edward Tuon Son** មានស្រុកកំណើតនៅ ភូមិចាក់ទទឹង(តៃយាំង) ស្រុកបាយឆៅ (ម៉ីស្វៀង)ខេត្តឃ្លាំង(សុកត្រាំង) កម្ពុជាក្រោម (មៀងណាំយៀក ណាំ) សព្វថ្ងៃយួនហៅថា ណាំបោ។

ឪពុកឈ្មោះ ស៊ីង ថុម(Thum Son)

ម្តាយឈ្មោះ ឡាង ធីហុន (Huol Thi Điên)

មានបងប្អូនបង្កើត៨នាក់ ប្រុស៣ ស្រី៥។

ទី១ ស៊ីង ធីហ៊ិន(ស្រី) សព្វថ្ងៃនៅកម្ពុជាក្រោម។

ទី២ ស៊ីង ទៀងហៅហ្វា(ប្រុស) សព្វថ្ងៃនៅសហរដ្ឋអាមេរិក។

ទី៣ ស៊ីង ធីហង្ស (ស្រី) សព្វថ្ងៃនៅកម្ពុជាក្រោម។

ទី៤ ស៊ីង ទួន (ប្រុស) សព្វថ្ងៃនៅសហរដ្ឋអាមេរិក(ស្លាប់)

ទី៥ ស៊ីង ធីកុង (ស្រី) សព្វថ្ងៃនៅសហរដ្ឋអាមេរិក។

ទី៦ ស៊ីង ធីភឹម (ស្រី) សព្វថ្ងៃនៅកម្ពុជាក្រោម។

ទី៧ ស៊ីង ធីហ៊ឹម (ស្រី) សព្វថ្ងៃនៅកម្ពុជាក្រោម។

ទី៨ ស៊ីង ព្រីង (ប្រុស) សព្វថ្ងៃនៅកម្ពុជាក្រោម។

លោក ស៊ីង ទួនបានចាកចេញពីស្រុកកំណើតនៅឆ្នាំ ១៩៧៨ ។ មករស់នៅជំរំជនភៀសខ្លួន ខៅអីដាំង ថ្ងៃទី២៨កុម្ភៈ ១៩៨០ ហើយបានរៀបការជាមួយនឹង អ្នកស្រី ថាច់ ហុង នៅក្នុងជំរំ ។ នៅក្នុងជំរំបានមួយ ឆ្នាំ ក៏បានទៅនៅកោះបាតាំង ប្រទេសហ្វីលីពីនចំនួន ៦ខែ។ លោកទួន និងគ្រួសារមកប្រទេសទីបី(សហរដ្ឋ អាមេរិក) នៅថ្ងៃទី២៧ ឧសភា ១៩៨១ នៅទីក្រុង ឡុងប៊ិច រដ្ឋកាលីហ្វញៀ សហរដ្ឋអាមេរិក។

លោកស៊ីង ទួននិងភរិយា បានរស់នៅ ប្រកបដោយ សុភមង្គល ហើយមានបុត្រធីតា ចំនួន៤នាក់គឺ

ទី១ ស៊ីង ពុទ្ធិកា (ស្រី)

ទី២ ស៊ីង លក្ខិណា (ស្រី)

ទី៣ ស៊ីង ខេមរារិទ្ធិ (ប្រុស)

ទី៤ ស៊ីង កនិដ្ឋា (ស្រី)

## ការសិក្សា

ពីកុមារភាពដល់យុវវ័យ បានបញ្ចប់ មហាវិទ្យាល័យ

នៅកម្ពុជាក្រោម។ មកដល់សហរដ្ឋអាមេរិក មានបំណែះវិជ្ជាខាងវិស្វករផ្នែកអេឡិកត្រូនិក (A Bachelor Degree in Electrical Engineering)។

## ការងារ

នៅឆ្នាំ១៩៧៥ **លោកសឺង ទូន** បានធ្វើជាចាងហ្វាងសាលាបឋមសិក្សានៅស្រុកបាយឆៅ ខេត្តឃ្លាំង កម្ពុជាក្រោម។ពេលនោះ គាត់បានប្រមែប្រមូលលោកគ្រូ អ្នកគ្រូខ្មែរក្រោមឲ្យចេះស្រឡាញ់រាប់អានគ្នា ចេះការពារគ្នាទៅវិញទៅមក ហើយនិងបណ្តុះបណ្តាលនូវស្មារតីស្នេហាជាតិមាតុភូមិជានិច្ចជាកាល

## ការបំរើជាតិ មាតុភូមិ កម្ពុជាក្រោម

ក្នុងចំណោមខ្មែរក្រោម រាប់ម៉ឺននាក់ ដែលមានវាសនាត្រូវបានវត្តុដ៏សក្តិសិទ្ធ ជំរុញឲ្យមកបំពេញតួនាទីដ៏ឧត្តមក្នុងការលាតត្រដាងនូវគំនរទុក្ខ សមុទ្រសោកនាដកម្ម នូវប្រវត្តិពិត។ ព្រឹត្តិការណ៍ដ៏ចុកឈាម របស់ជនរួមជាតិខ្មែរក្រោមយើងនៅកម្ពុជាក្រោម ដែលត្រូវអាណានិគមយួនគ្រប់សម័យកាល ធ្វើទុកបុកម្នេញ យ៉ាងព្រៃផ្សៃ យង់ឃ្នង ឃោឃៅជាទីបំផុតនោះ ជាពិសេសនៅសហរដ្ឋអាមេរិក ក្នុងជួរថ្នាក់ដឹកនាំ យើងបានឃើញលោកអតីតអធិបតីថាច់ តាន់តារា លោកអតីតប្រធានប្រតិបត្តិថាច់ ថើម **លោកអតីតប្រធានប្រតិបត្តិ សឺង ទូន។ យើងខ្ញុំ ក្នុងជួរគណៈកម្មការនាយកសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក បានដាក់ឈ្មោះឲ្យលោក សឺង ទូនថា "អ្នកបំរើជាតិ មិនចេះនឿយហត់"។**

ក្រោយពីបានទទួលសញ្ញាប័ត្រខាងវិស្វករមក លោក**សឺង ទូន** ក៏បានចូលប្រឡូកក្នុងការបំរើផលប្រយោជន៍ ជូនខ្មែរក្រោម។ មុនដំបូងគាត់បានបងប្អូនខ្មែរក្រោម នៅដំបន់កាលីខាងត្បូងរដ្ឋកាលីហ្វូនៀ ជ្រើសតាំងឲ្យធ្វើជាប្រធានសមាគម។

*ថ្ងៃទី៤សីហា១៩៩៦* លោក **សឺង ទូន** ត្រូវបានមហាសន្និបាតសកលលើកទី៥នៃខ្មែរកម្ពុជាក្រោមនៅក្រុងតូរនតូ ខេត្តអនតារីយោ ប្រទេសកាណាដា តែងតាំងឲ្យធ្វើជា អនុប្រធានសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក អាណត្តិកាល(១៩៩៦-២០០០) ដឹកនាំដោយលោកប្រធានថាច់ តាន់តារា។

*ថ្ងៃទី១ កក្កដា១៩៩៧* បានជួយតវ៉ាតាមផ្លូវទូត និងធ្វើអន្តរាគមន៍ឲ្យបងប្អូនខ្មែរក្រោម ដែលកំពុងរស់នៅក្នុង ជំរំស៊ុយវនៃប្រទេសថៃ ចំនួន៥៦រូបនិងព្រះសង្ឃ៣អង្គ មករស់នៅប្រទេសកម្ពុជា។

*ថ្ងៃទី២-៣សីហា១៩៩៧* បានចូលរួមប្រជុំការងារសហព័ន្ធនៅទីក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន សហរដ្ឋអាមេរិក។

*ថ្ងៃទី២២-២៣ កុម្ភៈ១៩៩៨* ចូលរួមប្រជុំការងារសហព័ន្ធនៅទីក្រុងតូរនតូ ប្រទេសកាណាដា ស្តីពីការសុំចូលយូអិនភីអូគឺ អង្គការប្រជាជាតិនិងប្រជាជនគ្មានតំណាង នៅក្នុងអង្គការសហប្រជាជាតិ( Unrepresented Nations and People Organization) ហើយដាក់ពាក្យសុំចូលនៅថ្ងៃទី៦មេសា។

*ថ្ងៃទី១ សីហា ១៩៩៨* ចូលរួមមហាសន្និបាត យុវជនខ្មែរក្រោមនៅក្រុងអារីស្សា រដ្ឋកាលីហ្វូនៀ សហរដ្ឋ ដើម្បីបង្កើតយុវជនខ្មែរក្រោមអន្តរជាតិ(Khmers-Krom International Youth)។

*ថ្ងៃទី២៨កញ្ញា១៩៩៨* បញ្ជូនប្រតិភូសហព័ន្ធ ៤អង្គនិងរូបទៅជួបមន្ត្រីអង្គការសហប្រជាជាតិ នៅក្រុងហ្សឺណែវ ប្រទេសស្វីស្ស។( Geneva, Swiss) ។ស្តីពីជំនឿសាសនាត្រូវរំលោភ។

ថ្ងៃទី២៣-២៤ វិច្ឆិកា ១៩៩៨ ប្រជុំការងារសហព័ន្ធ នៅក្រុងកូឡឹមបឹស រដ្ឋអូហៃអូ សហរដ្ឋ ស្តីពីផែនការនៅឆ្នាំខាងមុខ។

ថ្ងៃទី២១-២៩ធ្នូ ១៩៩៨ ចូលរួមបុណ្យខួបទី៦១ នៃទិវាបង្កើតមិត្តសមាគមខ្មែរក្រោមនៅបរទេស នៅទីក្រុងប៉ារីសប្រទេសបារាំង។ ហើយបានទៅធ្វើសវនាការ ជាមួយនឹងឯកឧត្តមសឺងសាន។

ថ្ងៃទី៥ កុម្ភៈ១៩៩៩ ជួបជាមួយលោកឈាន វ៉ម សួរប្រវត្តិបារាំងប្រគល់ទឹកដីកូសាំងស៊ីន ឲ្យយួនបាវដាយនៅឆ្នាំ១៩៤៩។

ថ្ងៃទី៤ កញ្ញា១៩៩៩ ចូលរួមប្រជុំការងារ សហព័ន្ធ ស្តីពីរចនាសម្ព័ន្ធរបស់សហព័ន្ធ។

ថ្ងៃទី១១-១២កញ្ញា ១៩៩៩ ទំនាក់ទំនងផ្លូវទូត ហើយបញ្ជូនប្រតិភូ២រូប គឺលោកថាច់ ង៉ុកថាច់ និងលោកប្រាក់ សេរីវុធ ទៅចូលរួមបាតុកម្មនៅមុខអង្គការ **អេប៉ែក**(APEC or Asian Pacific Economic Cooperation) នៅក្រុងអុកឡិន ប្រទេសនូវ៉ែលហ្សេឡង់( New zealand )។

ថ្ងៃទី២៨-២៩ វិច្ឆិកា ១៩៩៩ ចូលរួមប្រជុំការងារសហព័ន្ធ នៅក្រុងតាកូម៉ា រដ្ឋវ៉ាស៊ិនតោន សហរដ្ឋ ស្តីពីគំរោងបាតុកម្មនៅមុខអង្គការ ពាណិជ្ជកម្មពិភពលោក( WTO or World Trade Organization) ។

ថ្ងៃទី៣០ វិច្ឆិកា១៩៩៩ ដឹកនាំមហាបាតុកម្មជាប្រវត្តិសាស្រ្ត ស្តីពីសិទ្ធិមនុស្សនិងសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង នៅមុខអង្គការពាណិជ្ជកម្មពិភពលោក ដែលមានមនុស្សគ្រប់ជាតិសាសន៍ ចំនួនប្រាំម៉ឺននាក់ចូលរួម នៅក្រុងស៊ីអាថិល រដ្ឋវ៉ាស៊ិនតោន សហរដ្ឋអាមេរិក។

នៅពេលនោះ ភ្នាក់ងារវិទ្យុអាស៊ីសេរី បានមកធ្វើសំភាសន៍លោក**សឺង ទូន** អំពីគោលបំណង នៃការធ្វើបាតុកម្មនេះ។

ថ្ងៃទី១ ធ្នូ ១៩៩៩ អ្នកស្រី អាន នេងវិទ្យុសម្លេងសហរដ្ឋ បានទូរស័ព្ទ សូមសំភាសន៍លោក **សឺង ទូន** ស្តីពីមូលហេតុនៃការធ្វើបាតុកម្មនេះ ហើយរឿងដទៃទៀត ដែលទាក់ទងដល់ខ្មែរក្រោម។

ថ្ងៃទី១ មករា ២០០០ ទំនាក់ទំនងជាមួយលោកថាច់ សេដ្ឋា ប្រធានក្រុមចាត់ការកម្មវិធីបុណ្យ "សហសវត្សរ៍ថ្មី"ហើយក៏បញ្ជូនព្រះបណ្ឌិតមហាសាគុណចូលរួម ពីធីជាប្រវត្តិសាស្រ្តនេះ នៅរាជធានីភ្នំពេញ រាជាណាចក្រកម្ពុជា។

ថ្ងៃទី១២-១៣ មិនា ២០០០ ចូលរួមទូរសន្និបាត តាមប្រព័ន្ធទូរស័ព្ទ នៅទីក្រុងឡិកចាត រដ្ឋល្វីស្យាណា សហរដ្ឋអាមេរិក ស្តីពីការអនុម័ត យកថ្ងៃទី៤មិថុនា១៩៤៩ជាទិវាបាត់បង់ទឹកដី។

ថ្ងៃទី២២-២៧ ឧសភា ២០០០ សមាជិកប្រតិភូ សហព័ន្ធ ដឹកនាំដោយលោកប្រធាន ថាច់ តាន់តារា ដើម្បីទៅជួបនឹងតំណាងរាស្រ្ត ព្រឹទ្ធសមាជិក និងមន្ត្រីរដ្ឋការ អាគាំង នៅរដ្ឋធានីវ៉ាស៊ិនតោន ដើម្បីសូមឲ្យគេជួយដល់ខ្មែរក្រោម ដែលត្រូវអាណានិគមយួន រំលោភសិទ្ធិមនុស្ស និងជំនឿសាសនា ហើយនិង ផ្តល់អាហារូបករណ៍ ដល់និស្សិត ខ្មែរក្រោម នៅឯកម្ពុជាក្រោម។

ថ្ងៃទី១-២ កក្កដា ២០០០ សម្របសម្រួល ការបើកសិក្ខាសាលាសំរាប់ថ្នាក់ដឹកនាំសហព័ន្ធ"ជំនាន់សឺង គុយ"នៅក្រុងសែនភិប រដ្ឋផ្លរីដា សហរដ្ឋអាមេរិក។

ថ្ងៃទី៨ កញ្ញា ២០០០ ចូលរួមធ្វើមហាបាតុកម្មនៅមុខវិមាន

អង្គការសហប្រជាជាតិនៅបូរី នីវយ៉កដែលមាននាយករដ្ឋមន្ត្រី និងអ្នកដឹកនាំប្រទេសជាង១៥០ កំពុងប្រជុំ ក្នុងនោះមានយួន ដែរ។ ខ្មែរក្រោមនៅទ្វីបទាំងប្រាំជាង៣០០អង្គ-រូប បានមកចូលរួម គោលបំណងទាមទារឲ្យយួនហាណូយ បញ្ឈប់នយោបាយប្រល័យពូជសាសន៍ និងរំលោភសិទ្ធិមនុស្សមកលើខ្មែរក្រោម។

**ថ្ងៃសៅរ៍និងអាទិត្យ១១-១២កើត ខែភទ្របទ ឆ្នាំរោង ទោស័ក ព.ស.២៥៤៤ ត្រូវនឹងថ្ងៃទី៩-១០ កញ្ញា គ.ស.២០០០** ជាទិវាមហាសន្និបាតសកលលើកទី៦នៃខ្មែរកម្ពុជាក្រោម នៅបូរីនីវយ៉ក សហរដ្ឋអាមេរិក ហើយមានខ្មែរក្រោមនិមន្តនិងអញ្ជើញមកពីគ្រប់ទឹសទីក្នុងលោកចូលរួម មានព្រះសង្ឃ៥អង្គ ស្ត្រី៥រូប និងប្រុស១៥២នាក់។ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការនាយកនៃសហព័ន្ធខ្មែរកម្ពុជាក្រោម មានដូចតទៅ÷ លោកថាច់ តាន់តារា អធិបតី លោកថាច់ ចាន់ ប្រធានសភាព្រឹទ្ធាចារ្យ លោកថាច់ ធឿង ប្រធានសភាតំណាង **លោកស៊ឹង ទួន ប្រធានប្រតិបត្តិ** លោក តូ គឹមថុងអគ្គលេខាធិការ លោកថាច់ សេ ហេរញ្ញិក លោកត្រឹង ម៉ានរិទ្ធ និងលោកថាច់ ដួងសាង ឧបការីអធិបតី លោកថាច់ ង៉ុកថាច់អនុប្រធានប្រតិបត្តិ លោកប្រាក់ សេរីវុធ អនុប្រធានកិច្ចការបរទេស លោកថាច់ ធឿង អនុប្រធានប្រតិបត្តិប្រចាំទ្វីបអឺរុប លោកថាច់ អួងវ៉ា អនុប្រធានប្រតិបត្តិប្រចាំទ្វីបអូស្ត្រាលី និងលោកទៀ ថេន អនុប្រធានប្រតិបត្តិប្រចាំទ្វីបអាស៊ី។

**ថ្ងៃទី២០ ធ្នូ ២០០០** លោកស៊ឹង ទួន និងលោកប្រាក់ សេរីវុធ បានធ្វើសវនាការ ជាមួយនឹងអគ្គរដ្ឋទូតសហរដ្ឋ ប្រចាំរាជាណាចក្រកម្ពុជា ហើយសូម ស្ថានទូត ជួយដល់ខ្មែរក្រោមនៅកម្ពុជាផង។ ថ្ងៃដដែល ជួបជាមួយនឹងលោកសមរង្ស៊ី ប្រធានគណៈបក្សសមរង្ស៊ី។ នៅថ្ងៃដដែល បានទៅធ្វើសវនាការជាមួយនឹងសម្តេចសីហនុនិងព្រះជាយាមុនីនាថ ដើម្បីទូលថ្វាយ ពីផែនការតស៊ូដោយសន្តិវិធីរបស់សហព័ន្ធ ទ្រង់សព្វព្រះទ័យ ដោយបានប្រទាន លុយ២ពាន់ដុល្លារ៍សំរាប់ខ្មែរក្រោម និងមេដាយមាស ដល់ប្រតិភូទាំង៤រូបទៀតផង។

**ថ្ងៃទី២៤ ធ្នូ ២០០០** បានទៅធ្វើសវនាការ ជាមួយនឹងទ្រង់រណឫទ្ធិ ប្រធានរដ្ឋសភា ។ ទ្រង់ក៏បានគាំទ្រ ការតស៊ូរបស់សហព័ន្ធដែរ។

**ថ្ងៃទី២៧-២៨មករា ២០០១** ចូលរួមមហាសន្និបាតព្រះសង្ឃខ្មែរក្រោមពិភពលោក នៅក្រុងអែល អេ រដ្ឋកាលីហ្វញៀ សហរដ្ឋអាមេរិក ហើយសំរេចយកឈ្មោះថា"**សហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោមពិភពលោក**"( The United Association of Khmers Kampuchea –Krom Buddhist Monks )"ដែលមានព្រះគ្រូ ឡីវ ពៅ ជាប្រធាន។

**ថ្ងៃទី១៤-១៧ កុម្ភៈ ២០០១** ផ្ញើទូរសារឧទ្ទឹសនាមប្រតិភូសហព័ន្ធ៤រូបចូលរួមប្រជុំ អង្គការយូអិនភីអូ នៅក្រុងតាឡិន ប្រទេសអេះតូនៀ(The Tallin city of Estonia, former Soviet Union) លទ្ធផល សន្និសិទយូអិនភីអូបានសំរេចថា នឹងឲ្យសហព័ន្ធខ្មែរកម្ពុជាក្រោម ចូលជាសមាជិកពេញអង្គ នៅក្នុងរយៈពេល៦ខែទៀត ដោយគិតតាំងពីខែកុម្ភៈនេះទៅ។

**ថ្ងៃទី៣១ មិនា ២០០១** ចូលរួមពិធីបុណ្យចូលឆ្នាំខ្មែរ នៅទីក្រុងឡូ រដ្ឋម៉ាស្សាចូសែត សហរដ្ឋអាមេរិក។

**ថ្ងៃទី១៩-២០ ឧសភា២០០១** សម្រប់សម្រួលការបើកសិក្ខាសាលាសំរាប់ថ្នាក់ដឹកនាំសហព័ន្ធ"**ជំនាន់ថាច់ ចាន់**" នៅក្រុងដាឡាស រដ្ឋតែកសាស្ស សហរដ្ឋអាមេរិក។

**ថ្ងៃទី១ មិថុនា ២០០១** វិទ្យុផ្សាយ សម្លេងកម្ពុជាក្រោម ជាប់ផ្សាយជាផ្លូវការនៅរាល់ថ្ងៃអង្គារ៍ ពីម៉ោង៩ដល់១០យប់

ម៉ោងនៅកម្ពុជាក្រោម យើងបានជួលយន្តរណប (Satlelite) មួយរបស់ប្រទេសបែលហ្សិក សំរាប់ផ្សាយដំណឹងក្នុង១ម៉ោង ៤០០ដុល្លារ៍សហរដ្ឋ។ ស្ថាប័នដ៏ប្រណិតរបស់សហព័ន្ធ គឺ ដឹកនាំដោយ លោកអធិបតី និងប្រធានប្រតិបត្តិ។

ថ្ងៃទី១៥ កក្កដា ២០០១ ចូលជាសមាជិកពេញច្បាប់ នៃអង្គការយូអិនភីអូ។

ថ្ងៃទី១ សីហា ២០០១ សហព័ន្ធ បានចូលជា សមាជិកនៃ សហព័ន្ធទូក-ងអន្តរជាតិ(International Dragon Boat Federation or IDBF) ទូក-ងខ្មែរក្រោម មានឈ្មោះថា **កំហែងនាគរាជ**។ ហើយកីឡាករ-ការិនីទូក-ងខ្មែរក្រោម ក៏បាន ទទួលមេដាយមាស ក្នុងពេលនេះដែរ។ ថែមពីលើនោះទៀត ថាសចំរៀងស្នេហាជាតិលេខ១ ដែលច្រៀងដោយ កញ្ញាទូច ស៊ុននិច លោកសយ វិឡ្សនី អ្នកចំរៀងឈានមុខ នៃសុបិន ខ្មែរក្រោម ក៏បានមកកំដរអារម្មណ៍ ដល់បងប្អូនយើងនៅក្នុង ឱកាសជាប្រវត្តិសាស្ត្រនេះដែរ។

ថ្ងៃទី១០-១៣ មករា ២០០២ ចូលរួមប្រជុំការងារសហព័ន្ធ នៅក្រុងតូរនតូ ប្រទេសកាណាដា ស្តីពីការអនុម័តធម្មនុញ្ញ សហព័ន្ធ។

ថ្ងៃទី២៥ កុម្ភៈ ២០០២ លោកប្រធានប្រតិបត្តិ និងសហការី ៤នាក់ទៀត បានធ្វើសវនាការជាមួយនឹងអ្នកស្រី ឡូរី សាត្រីវ៉ា មន្ត្រីមូលនិធិទ្រទ្រង់លទ្ធិប្រជាធិបតេយ្យ នៅរដ្ឋធានី វ៉ាស៊ិនតោន សហរដ្ឋអាមេរិក ស្តីពីការសុំជំនួយ និងទៅទីស្តីការក្រសួងការបរទេសអាមេរិក ដើម្បីឲ្យបានដឹងពីនយោបាយអាមេរិក ចំពោះយួន។

ថ្ងៃទី២៥-២៦ ឧសភា ២០០២ សម្របសម្រួល ការបើកសិក្ខាសាលាសំរាប់ថ្នាក់ដឹកនាំសហព័ន្ធ"**ជំនាន់ឡឹម អែម**" នៅ ក្រុងភីឡាដែលហ្វា រដ្ឋប៉ែនស៊ីវ៉ានៀ សហរដ្ឋអាមេរិក។

ថ្ងៃទី៩ មិថុនា ២០០២ ធ្វើសន្និសីទសារពត៌មានតាមបណ្តាញទូរស័ព្ទ នៅជុំវិញពិភពលោក ក្រោមប្រធានបទ"**ខ្មែរក្រោម និង៥៣ឆ្នាំក្រោមរបបអាណានិគមយួន**"។

ថ្ងៃទី១៥ មិថុនា ២០០២ លោកប្រធានប្រតិបត្តិ ផ្ញើសារមួយច្បាប់ ជូនលោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលជំហរសហព័ន្ធ ទាក់ទិននិងបញ្ហាខ្មែរក្រោម កំពុងរស់នៅកម្ពុជាសព្វថ្ងៃ។

ថ្ងៃទី២២ កក្កដា ២០០២ លោកប្រធានប្រតិបត្តិ ផ្ញើសារមួយច្បាប់ ជូនលោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ស្តីពីសំណុំពរ៣ប្រការ(អត្ថឆ័យ ជួយការពារ យុត្តិធម៌ឲ្យខ្មែរក្រោម កំពុងរស់នៅកម្ពុជា)។

ថ្ងៃទី៤ កញ្ញា ២០០២ លោកប្រធានប្រតិបត្តិ និងសមាជិកគណៈកម្មការនាយក បានសុំពរត្រជាក់ត្រជុំ និងអត្តសញ្ញាណខ្មែរក្រោម ពីសម្តេចប៉ាប នៅបូរីវ៉ាទីកាំង ប្រទេសអ៊ីតាលី។ ក្នុងឱកាស សហព័ន្ធចូលរួម ការប្រណាំងទូក-ង ជាលក្ខណៈអន្តរជាតិនៅប្រទេសនេះ។

ថ្ងៃទី៥-៦ ធ្នូ ២០០២ បញ្ជូនប្រតិភូសង្ឃ ទៅចូលរួមសន្និសីទកំពូលពុទ្ធសាសនាលើកទី៣ នៅក្រុងភ្នំពេញ រាជាណាចក្រកម្ពុជា នៅឱកាសនេះ ព្រះគ្រូលីវ ពៅបានផ្សព្វផ្សាយឯកសារជាត្រីភាសាស្តីពីរឿងរ៉ាវខ្មែរក្រោមជូនអង្គសន្និបាត។

ថ្ងៃទី១៥-១៦ មិនា ២០០៣ ចូលរួមប្រជុំការងារ ប្រចាំឆ្នាំនៃសហព័ន្ធ នៅវត្តកម្ពុជាក្រោម ក្រុងហាមិញតុន ប្រទេសកាណាដា ស្តីពីផែនការសហព័ន្ធ សំរាប់ឆ្នាំ២០០៣។

ថ្ងៃទី៤ មិថុនា ២០០៣ លោកប្រធានប្រតិបត្តិ បានថ្លែងការណ៍យ៉ាងវែង តាមវិទ្យុ "**សម្លេងកម្ពុជាក្រោម**" ស្តីពី

ខ្មែរក្រោម និង៥៥ឆ្នាំ ក្រោមរបបអាណានិគមយួន"។

ថ្ងៃទី១៤-១៥ មិថុនា ២០០៣ ចូលរួមសន្និសិទប្រចាំឆ្នាំ នៃសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោមពិភពលោក ក្រោមអធិបតីភាពរបស់ព្រះគ្រូលីវ ពៅ នៅវត្តចន្ទសង្សី ក្រុងតាកូម៉ា រដ្ឋវ៉ាស៊ិនតោន សហរដ្ឋអាមេរិក។

ថ្ងៃទី១៩-២០ កក្កដា ២០០៣ ចូលរួមការប្រជុំកំពូល នៃការងារសហព័ន្ធ ស្តីពីស្ថាប័នទាំងបី នៃសហព័ន្ធ និងផែនការសំរាប់ឆ្នាំ២០០៣-០៤ នៅក្រុងម៉ុងរ៉េអាលប្រទេសកាណាដា។

ថ្ងៃទី១៦ សីហា ២០០៣ លោកអធិបតី និងប្រធានប្រតិបត្តិ ចូលរួមភោជនាហារជាកិត្តិយស និងធ្វើសវនាការជាមួយនឹងលោកប្រធានាធិបតីសហរដ្ឋ George W.Bush នៅរដ្ឋកាលីហ្វញ៉ា។

ថ្ងៃទី២០ កញ្ញា ២០០៣ ចូលរួមនឹងប្រតិភូ យូអិនភីអូ ដែលអញ្ជើញមកពីអឺរ៉ុប និងបណ្ឌិត COOPER មកពីហាវ៉ាយ មកធ្វើអត្ថាធិប្បាយ ស្តីពីដំណើរឆ្ពោះទៅកាន់ សិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង នៅសណ្ឋាគារហូលីដេ រដ្ឋនីវជើស៊ី សហរដ្ឋអាមេរិក។ ថ្ងៃទី២១ កញ្ញា ទៅរដ្ឋ ម៉ាស្សាជូសែត ថ្ងៃទី២៦ កញ្ញា ទៅរដ្ឋ កាលីហ្វញ៉ា ថ្ងៃទី២៨ កញ្ញា ទៅរដ្ឋវ៉ាស៊ិនតោន ។

ថ្ងៃទី១៩ ធ្នូ ២០០៣ លោកប្រធានប្រតិបត្តិ បានផ្ញើសារអបអរសាទរ ចំពោះប្រជាជាតិទាំងបី គឺ Ahwazi នៅប្រទេសអៀរ៉ង់ ជាតិ Hvavenda នៅប្រទេសអាហ្វ្រិកខាងត្បូង និង Montagnard នៅយួនភាគកណ្តាល ដែលជាសមាជិកថ្មីនៃអង្គការ យូអិនភីអូ ដែលមានទីស្នាក់ការនៅ ក្រុងឡាអេ។

ថ្ងៃទី២-៤មករា ២០០៤ ចូលរួមប្រជុំ ការងារប្រចាំឆ្នាំរបស់សហព័ន្ធ នៅក្រុងសង់ហូសេ រដ្ឋកាលីហ្វញ៉ា សហរដ្ឋ។

ថ្ងៃទី៩ មករា ២០០៤ ផ្ញើសារសម្តែងការសាទរ ចំពោះសម្ព័ន្ធសមណនិស្សិត និងនិស្សិតខ្មែរក្រោម នៅភ្នំពេញ កម្ពុជា។

ថ្ងៃទី២២ មករា ២០០៤ លោកប្រធានប្រតិបត្តិ បានធ្វើសំភាសន៍ជាមួយ នឹងលោកសំ បូរិន្ទ នៃវិទ្យុអាស៊ីសេរី ស្តីពីផែនការឆ្នាំ២០០៤ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម។

ថ្ងៃទី២៧-២៨ មិនា ២០០៤ ចូលរួមវគ្គបណ្តុះបណ្តាល-ពីសិទ្ធិមនុស្ស ដល់សមាជិក សមាជិកា សហព័ន្ធ នៅក្រុងសង់ហូសេ រដ្ឋកាលីហ្វញ៉ា សហរដ្ឋអាមេរិក។

ថ្ងៃទី១០ ឧសភា ២០០៤ លោកស៊ឺង ទួន ប្រធានប្រតិបត្តិ **ជាអ្នកឈានមុខនៃសុបិនខ្មែរក្រោម** ដែលដឹកនាំគណៈប្រតិភូសហព័ន្ធ ចូលប្រជុំនៅអង្គការសហប្រជាជាតិ ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រខ្មែរក្រោម"**វេទិកាអចិន្ត្រៃយ៍នៃសហប្រជាជាតិស្តីពីជនជាតិពន្ធ**(ជាតិដើម) ដែលហៅកាត់ថា **UNPFII** *or* **The United Nations Permanent Forum in Indigenous Issues** នៅ ញូវយ៉ក សហរដ្ឋអាមេរិក។

ថ្ងៃទី៥-៦ មិថុនា ២០០៤ លោកស៊ឺង ទួន ប្រធានប្រតិបត្តិ ចូលរួមមហាសន្និបាត សហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោមពិភពលោក នៅវត្តរតនារាម ក្រុងស៊ីដនី រដ្ឋនីវសៅវ៉េវ ប្រទេស អូស្ត្រាលី ដឹកនាំដោយព្រះគ្រូលីវ ពៅដែលជាសង្ឃាធិបតីនៃព្រះសង្ឃខ្មែរក្រោមពិភពលោក។

ថ្ងៃទី៣-៤ កញ្ញា២០០៤ មហាសន្និបាតសកលលើកទី៧នៃខ្មែរកម្ពុជាក្រោម នៅក្រុងខេមឌិន រដ្ឋនីវជើស៊ី សហរដ្ឋអាមេរិក បានជ្រើសតាំង លោកសឺង ទូន ជាទីប្រឹក្សាគណៈកម្មការនាយកនៃសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកអាណត្តិកាល ២០០៤-២០០៧។

អនិច្ចំ ទុក្ខំ អនត្តា កើតមកជាមនុស្ស ស្លាប់រស់ ជាគូនឹងគ្នា។ លោកសឺង ទូន ជាក្រុមអ្នកឈានមុខនៃសុបិនខ្មែរក្រោម ជាក្រុមអ្នកកាន់ចង្កូតនាវាខ្មែរក្រោមឆ្ពោះទៅកាន់ "**សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង**"។ កំពុងតែធ្វើដំណើរស្រាប់តែត្រូវរោគាមកបៀតបៀនគឺគាត់មានជំងឺ"មហារីកបំពង់ក" នៅចុងឆ្នាំ២០០៣។ប្រពន្ធនិងកូនចៅ បានយកគាត់ទៅព្យាបាលនៅមន្ទីពេទ្យ យូស៊ី ក្រុងដែលអេ ក្រុងនីវយ៉ក ឡុងបិឆនិងវេសមិញទើ។ល។ តាំងពីនោះរហូតមក ដល់ថ្ងៃអាទិត្យ ២កើត ខែផល្គុន ឆ្នាំចអដ្ឋស័ក ព.ស.២៥៥០ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ គ.ស.២០០៧ លោកសឺង ទូន ក៏បានទទួលមរណភាពនៅវេលាម៉ោង ២រសៀល(ម៉ោងនៅរដ្ឋកាលីហ្វញៀ. សហរដ្ឋ) ក្នុងមន្ទីពេទ្យតែម្តង ក្នុងជន្មាយុ ៥១ឆ្នាំ។

មរណភាពរបស់ លោកសឺង ទូន អតីតប្រធានសហព័ន្ធ ខ្មែរកម្ពុជាក្រោម ធ្វើឱ្យយើងខ្ញុំ ជាសមាជិក សមាជិកានៃសហព័ន្ធខ្មែរកម្ពុជាក្រោម តាំងពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់ជាន់ក្រោមមួយអន្លើដោយប្រជាពលរដ្ឋខ្មែរក្រោម ជាងដប់លាននាក់នៅជុំវិញពិភពលោក ជាពិសេស នៅមាតុភូមិកម្ពុជាក្រោមដ៏សែនស្រណោះរបស់យើង មានការសោកស្តាយខ្លាំងណាស់។ ព្រោះយើងត្រូវបាត់បង់វីរជនមួយរូប ក្នុងដំណើរស្វែងរកសិទ្ធិសេរីភាព ជូនជាតិមាតុភូម ជាទីគោរពស្នេហារបស់យើង។

ថ្វីបើរូបនិងកាយបានស្លាប់ទៅក៏ពិតមែន តែស្នាដៃទាំងឡាយដែលលោកបានសាង ដើម្បី បំរុង និងថែពារខ្មែរក្រោមនោះ កូនចៅខ្មែរក្រោមជំនាន់ក្រោយ មិនអាចបំភ្លេចបាន ហើយអាចបំភ្លេចបានជារៀងរហូត។

សូមវិញ្ញាណក្ខន្ធលោកអតីតប្រធាន សឺង ទូន បានទៅកាន់សុគតិភព។ សូមលោកស្រី **សឺង ទូន** នាមដើម **ថាច់ ហុង និងបុត្រធីតាទាំងអស់ មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ** ជាគណៈកម្មការនាយក-សាខា-សមាគម -វត្តអារាមនៃសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោកមួយអន្លើ ដោយប្រជាពរដ្ឋខ្មែរក្រោម ជាង១០លាននាក់ នៅមាតុភូមិកម្ពុជាក្រោមដ៏សែនស្រណោះរបស់យើង។

ធ្វើនៅ សហរដ្ឋអាមេរិក ថ្ងៃទី២៥ កុម្ភៈ ២០០៧

ការិយាល័យបណ្ណសារនៃ

សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក

